00533229

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

លេខ/No: -6-

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/អបជ (០៧)**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

---

**សាធារណៈ:**

**សាលដីកាលើពាក្យបណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ របស់លោក អៀង សារី និង លោកស្រី អៀង ធីរិទ្ធ ប្តឹងដិតចិត្តចៅក្រម MARCEL LEMONDE**

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 06 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉ែត ចរិយា
William SMITH

**ជនត្រូវចោទ**
អៀង សារី
អៀង ធីរិទ្ធ
នួន ជា

**សហចៅក្រមស៊ើបអង្កេត**
Marcel LEMONDE

**សហមេធាវីការពារក្តីជនត្រូវចោទ**
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS QC

សុន អរុណ
Michiel PESTMAN
Victor KOPPE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួលបណ្តឹងចំនួនពីរ ដែលបានប្តឹងដិតចិត្តសហចៅក្រមស៊ើបអង្កេតមួយរូបគឺលោកចៅក្រម Lemonde។

## I. **ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទ អៀង ធីរិទ្ធ បានដាក់បណ្តឹងដិតចិត្តចៅក្រម Lemonde គឺ “ពាក្យបណ្តឹងរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ប្តឹងដិតចិត្តសហចៅក្រមស៊ើបអង្កេតលោក Marcel Lemonde” (“បណ្តឹងដិតចិត្តរបស់ អៀង ធីរិទ្ធ”)[១]។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទ អៀង សារី បានដាក់ “បណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ លើកទី២ របស់លោក អៀង សារី សុំប្តឹងដិតចិត្តចៅក្រម Marcel Lemonde និងការសុំចូលរួមក្នុងបណ្តឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំប្តឹងដិតចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំឱ្យមានសវនាការជាសាធារណៈ” (“បណ្តឹងដិតចិត្តរបស់ អៀង សារី”)[២]។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទ នួន ជា បានជូនដំណឹងអំពីបំណងរបស់កូនក្តីខ្លួន ចង់ចូលរួមនៅក្នុងបណ្តឹងដិតចិត្តរបស់ អៀង ធីរិទ្ធ (“សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា”)[៣]។

---

[១] ពាក្យបណ្តឹងរបស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្តឹងដិតចិត្តសហចៅក្រមស៊ើបអង្កេតលោក Marcel Lemonde រឿងក្តីលេខ ០០២/០៧-១២-២០០៩-អវតក/អបជ(០៥) ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ១ ERN ០០៤១១០១០-០០៤១១០២៦ (“បណ្តឹងដិតចិត្តរបស់ អៀង ធីរិទ្ធ”)។

[២] បណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ លើកទី២ របស់លោក អៀង សារី សុំប្តឹងដិតចិត្តចៅក្រម Marcel Lemonde និងការសុំចូលរួមក្នុងបណ្តឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំប្តឹងដិតចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំឱ្យមានសវនាការជាសាធារណៈ” រឿងក្តីលេខ ០០២/១១-១២-២០០៩-អវតក/អបជ(០៧) ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ១ ERN ០០៤១៤១៦០-០០៤១៤១៧៩ (“បណ្តឹងដិតចិត្តរបស់ អៀង សារី”)។

[៣] សេចក្តីជូនដំណឹងអំពីបណ្តឹងរួមចំពោះ “ពាក្យបណ្តឹងដិតចិត្តរបស់មេធាវីការពារក្តី អៀង ធីរិទ្ធចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde” ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ៣ ERN ០០៤១៦៦៩៤-០០៤១៦៦៩៦ (“សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា”)។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

២. នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ចៅក្រម Lemonde បានស្នើសុំពន្យាររយៈពេលឆ្លើយតបទៅនឹងបណ្តឹងរបស់ អៀង សារី រហូតដល់ដប់ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីបណ្តឹងជំទាស់ជាភាសាបារាំង[៤]។ នៅថ្ងៃដដែល ចៅក្រម Lemonde បានដាក់សំណើដូចគ្នាចំពោះបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ[៥]។

៣. សហមេធាវីការពារក្តីជនត្រូវចោទ អៀង សារី បានដាក់សេចក្តីបន្ថែមចំពោះបណ្តឹងជំទាស់របស់ខ្លួននៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ដោយបានភ្ជាប់កំណត់ត្រាសរសេរដោយដៃរបស់លោក Bastin[៦]។

៤. នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបរួមទៅនឹងបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ និង អៀង សារី[៧]។

៥. យោងតាមលិខិតចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ ចៅក្រម Lemonde បានជូនដំណឹងដល់អង្គបុរេជំនុំជម្រះថា ខ្លួនបានដឹងថាមាន ១) បណ្តឹងជំទាស់របស់ អៀង សារី និងសេចក្តីបន្ថែមទៅនឹងបណ្តឹង ២) បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ ៣) សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់សហមេធាវីការពារក្តី នួន ជា និង ៤) បណ្តឹងជំទាស់តាមវិធានផ្ទៃក្នុង

---

[៤] ការជូនដំណឹងអំពីភាសានៃការដាក់ និងទទួលពាក្យសុំ និងសំណើសុំពន្យាពេលដើម្បីឆ្លើយតបនឹងពាក្យសុំទាំងឡាយ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ហើយបានជូនដំណឹងនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ២ ERN ០០៤១៦៦៩២-០០៤១៦៦៩៣។

[៥] ការជូនដំណឹងអំពីភាសានៃការដាក់ និងទទួលពាក្យសុំ និងសំណើសុំពន្យាពេលដើម្បីឆ្លើយតបនឹងពាក្យសុំទាំងឡាយ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ហើយបានជូនដំណឹងនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ២ ERN ០០៤១៦៦៩២-០០៤១៦៦៩៣។

[៦] សេចក្តីបន្ថែមចំពោះសំណើលើកទី២ របស់ អៀង សារី ស្នើសុំអនុវត្តវិធាន ៣៤ ដើម្បីប្តឹងជំទាស់ចៅក្រម Marcel Lemonde ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ៣ ERN ០០៤១៧២៥៥-០០៤១៧២៥៦ ("សេចក្តីបន្ថែមរបស់ អៀង សារី")។

[៧] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងជំទាស់របស់លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ៤ ERN ០០៤១៦៨៧៥-០០៤១៦៨៨៨ ("ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា")។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00533233



៣៥ របស់សហមេធាវីការពារក្ដី អៀង សារី[៨]។ ចៅក្រម Lemonde បានឆ្លើយតបត្រង់ផ្នែកមួយចំនួន ដោយបានចង្អុលយោងលើបញ្ហានានាដែលបានលើកឡើងនៅក្នុងដីកា ដែលបានចេញនាពេលថ្មីៗដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប[៩]។

៦. នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ សហមេធាវីការពារក្ដីជនត្រូវចោទ អៀង ធីរិទ្ធ បានដាក់សេចក្ដីស្នើសុំបន្ថែម[១០] ហើយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ សហមេធាវីការពារក្ដីបានដាក់សំណើសុំបង្ហាញឯកសារ ហើយអង្គបុរេជំនុំជម្រះបានទទួលយកសំណើនេះ[១១]។

## II. សង្ខេបសេចក្ដីសន្និដ្ឋាន

៧. សហមេធាវីការពារក្ដី អៀង ធីរិទ្ធ បានផ្អែកបណ្ដឹងជំទាស់ដាក់លើសេចក្ដីថ្លែងការណ៍របស់លោក Bastin ដែលជាអតីតបុគ្គលិករបស់ ក.ស.ច.ស។ សេចក្ដីថ្លែងការណ៍នេះបានផ្ដល់ជូននៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ និងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩។ ទឡ្ហីករណ៍

---

[៨] លិខិត ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ ដែលបានទទួលនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១០ ERN ០០៤២៣៦៩៩-០០៤២៣៧០០ ឯកសារលេខ ៥។

[៩] ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំឲ្យធ្វើកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ (ជូនដំណឹងនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១០) ឯកសារលេខ ៥.១ ERN ០០៤២២៦០៧-០០៤២២៦១៨ [ឯកសារលេខ D263/1 ក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស]។

[១០] សេចក្ដីស្នើសុំបន្ថែមទៅនឹងពាក្យបណ្ដឹងរបស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ ប្ដឹងជំទាស់សហចៅក្រមស៊ើបអង្កេតលោក Marcel Lemonde ថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ ឯកសារលេខ ៦ ERN ០០៤២៣៥៥៨-០០៤២៣៥៦២ ("សេចក្ដីស្នើសុំបន្ថែមរបស់ អៀង ធីរិទ្ធ")។

[១១] សំណើសុំបង្ហាញឯកសារយោងក្នុងចម្លើយតបរបស់ចៅក្រម Marcel Lemonde ទៅនឹងពាក្យបណ្ដឹងរបស់មេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ ប្ដឹងជំទាស់សហចៅក្រមស៊ើបអង្កេតលោក Marcel Lemonde ០០២/០៧-១២-២០០៩-អវតក/អបជ(០៥) ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០។ សំណើនេះត្រូវបានចាត់ការរួចរាល់តាមរយៈអ៊ីម៉ែលដោយក្រឡាបញ្ជីអង្គបុរេជំនុំជម្រះឆ្លើយឆ្លងជាមួយមន្ត្រីទទួលសំណុំរឿងរបស់អវតក ដែលអនុញ្ញាត សហមេធាវីការពារក្ដីត្រូវបានអនុញ្ញាតិតាមសំណើចូលមើលសំណុំរឿង ០០២ ។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ដែលបានលើកឡើងនៅក្នុងបណ្តឹងជំទាស់ទាំងបីនោះ អាចយកមកធ្វើការសង្ខេបដូចខាងក្រោម៖

ក. "ចៅក្រម Lemonde បានបង្ហាញឱ្យឃើញយ៉ាងជាក់ស្តែងអំពីភាពលម្អៀងចំពោះការស្វែងរកភស្តុតាងដាក់បន្ទុក ជៀសជាងភស្តុតាងដោះបន្ទុកនៅក្នុងការស៊ើបសួរ" [១២]។

ខ. "ចៅក្រម Lemonde ខកខានមិនបានរក្សានូវការបែងចែកអំណាចរវាងអង្គភាពការចោទប្រកាន់ និងអង្គភាពវិនិច្ឆ័យក្តី" នៅពេលទទួលក្រៅផ្លូវការនូវឯកសារមួយពីសមាជិកម្នាក់នៃការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") [១៣]។

គ. ចៅក្រម Lemonde គួរតែត្រូវបានដកចេញពីការបន្តតួនាទី ដោយសារតែ "សេចក្តីអះអាងមិនត្រឹមត្រូវថាជាច្បាប់ នៅក្នុងដីកាសម្រេចលើសំណើសុំឱ្យមានកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ("SMD")" [១៤]។

ឃ. ចៅក្រម Lemonde គួរតែត្រូវបានដកចេញពីការបន្តតួនាទី ដោយសារតែ "ភាពស្ទាក់ស្ទើររបស់គាត់ក្នុងការចង្អុលបង្ហាញឱ្យបានត្រឹមត្រូវចំពោះភស្តុតាងដោះបន្ទុកនៅក្នុងដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន" [១៥]។

ង. សេចក្តីថ្លែងការណ៍របស់ចៅក្រម Lemonde ទៅកាន់សារព័ត៌មានបានបង្ហាញបន្ថែមទៀតចំពោះភាពលម្អៀងរបស់គាត់លើរឿងក្តីដែលត្រូវចោទប្រកាន់ [១៦]។

ច. ចៅក្រម Lemonde "ត្រូវមានការទទួលខុសត្រូវចំពោះគោលនយោបាយមួយដែលត្រូវបានបង្កើតនៅក្នុង ក.ស.ច.ស អំពីការលាក់ ឬការប៉ុនប៉ងលាក់ព័ត៌មានពី 'ខាងភាគីខ្មែរ' នៅក្នុង ក.ស.ច.ស ដោយរួមទាំងលោកចៅក្រម យូ ប៊ុនឡេង"។ បញ្ហានេះ បានបង្កើតឱ្យមាននូវ "ការរំលោភទៅលើគោលការណ៍នៃការស្រុះស្រួលគ្នា ក្នុងការធ្វើសេចក្តីសម្រេចរវាងបុគ្គលិកជាតិ និងអន្តរជាតិ" [១៧]។

ឆ. ចៅក្រម Lemonde បានបង្ហាញឱ្យឃើញនូវកង្វះសុចរិតភាព ដោយសារគាត់យល់ព្រម "ឱ្យប្រើប្រាស់នូវការថតខ្សែអាត់ដោយសម្ងាត់ចំពោះការសម្ភាសសាក្សីសំខាន់ៗទាំងឡាយ និងគាត់បានអនុញ្ញាតឱ្យពួកគេថតខ្សែភាពយន្តដោយលួចលាក់" [១៨]។

---

[១២] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី២ និងកថាខណ្ឌទី១១ (ក)។

[១៣] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៣ និងកថាខណ្ឌទី១១ (ង)។

[១៤] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៤ (i)។

[១៥] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៤ (ii)។

[១៦] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៤ (iii)។

[១៧] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៥ និងកថាខណ្ឌទី១១ (ឃ)។

[១៨] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៦ និងកថាខណ្ឌទី១១ (ខ)-(គ)។

អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ជ. កង្វះសុចរិតភាពរបស់ចៅក្រម Lemonde បានបង្ហាញបន្ថែមតាមរយៈករណី ដែលគាត់ "បានណែនាំឱ្យអ្នកនៅក្រោមបង្គាប់គឺលោក Bastin កែប្រែរបាយការណ៍វាយតម្លៃ ដែលរូបគាត់បានរៀបចំឡើងសម្រាប់សមាជិកក្រុមមួយរូបទៀត ដើម្បីធ្វើឱ្យប្រសើរឡើងចំពោះឱកាសរបស់សមាជិកក្រុមរូបនោះក្នុងការទទួលបានការបន្តកិច្ចសន្យាការងារ" [១៩]។

ឈ. នៅក្នុងខែកញ្ញា ឆ្នាំ២០០៩ លោកចៅក្រម Lemonde "បានប៉ុនប៉ងរិតត្បិតព័ត៌មានដែលរសើបនៃ "កម្មវិធីលើសាក្សីផ្ទៃក្នុង" សម្រាប់តែ "បុគ្គលិកអន្តរជាតិ"នៃ ក.ស.ច.ស" [២០]។

៨. សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានសន្និដ្ឋានថា ផលវិបាកដែលចេះតែកើនឡើងនៃបញ្ហាទាំងនេះគឺមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមានអន្តរាយដល់ដំណើរការប្រកបដោយយុត្តិធម៌ និងបានធ្វើឱ្យប៉ះពាល់មិនល្អដល់សិទ្ធិទទួលបាននូវការស៊ើបសួរដោយយុត្តិធម៌ និងមិនលម្អៀងរបស់ជនត្រូវចោទ [២១]។

៩. យោងតាមសេចក្តីស្នើសុំបន្ថែមរបស់ខ្លួន សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានចង្អុលយោងលើសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលបានសម្រេចកាលពីលើកមុនលើបណ្តឹងតាមវិធាន ៣៤ ហើយជាពិសេស សហមេធាវីការពារក្តីបានយោងលើករណីដែលថា អង្គបុរេជំនុំជម្រះ "បានរងឥទ្ធិពលនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនតាមរយៈការខកខានរបស់មេធាវីការពារក្តីរបស់លោក អៀង សារី ក្នុងការទទួលបានសេចក្តីថ្លែងអះអាងពីជនដទៃទៀត ដែលមេធាវីការពារក្តីអះអាងថា បានដឹងអំពីព្រឹត្តិការណ៍នោះដែលជាប្រធានបទនៃបណ្តឹង [២២]។ សហមេធាវីការពារក្តីបានសន្និដ្ឋានថា ការសម្ភាសន៍សមាជិកនៃ ក.ស.ច.ស ដើម្បីយកសេចក្តីថ្លែងអះអាងនឹងមានលក្ខណៈមិនសមស្របឡើយ បើទោះជាសហមេធាវីការពារក្តីបានសង្កត់ធ្ងន់ផងដែរថា ក្នុងករណីចាំបាច់ ខ្លួននឹងធ្វើការសម្ភាសន៍ប៉ុន្តែខ្លួននឹងសុំការណែនាំពីអង្គបុរេជំនុំជម្រះនៅក្នុងករណីនេះ។

---

[១៩] បណ្តឹងជិតចិត្តរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី៦ និងកថាខណ្ឌទី១១ (ផ)។

[២០] បណ្តឹងជិតចិត្តរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី១១(ច)។

[២១] បណ្តឹងជិតចិត្តរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី៧។

[២២] សេចក្តីស្នើសុំបន្ថែមរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី៨។

១០. ឯកសារខាងក្រោមនេះ ត្រូវបានដាក់មកជាមួយនឹងសេចក្តីស្នើសុំបន្ថែមរបស់ អៀង ធីរិទ្ធ[២៣]៖

ក. សេចក្តីថ្លែងអះអាងដែលបានធ្វើឡើងដោយមន្ត្រីនគរបាលមួយរូបរបស់រដ្ឋវិចថូរៀនៃប្រទេសអូស្ត្រាលីថា លោក Bastin គឺជាម្ចាស់នៃសេចក្តីថ្លែងការណ៍ទាំងនោះ ហើយមន្ត្រីនគរបាលរូបនេះក៏បានផ្ទៀងផ្ទាត់ថា គាត់ពិតជាម្ចាស់នៃ "កំណត់ត្រាខ្លីៗ" ពិតប្រាកដមែន។

ខ. កំណត់ត្រាខ្លីៗ ដែលបានកត់ត្រាដោយលោក Bastin នៅក្នុងកិច្ចប្រជុំខែសីហា ឆ្នាំ២០០៩។

គ. កំណត់ពន្យល់ដោយលោក Bastin អំពីកំណត់ត្រាខ្លីៗរបស់ខ្លួន។

១១. សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកឯកសារទាំងនេះ ហើយសុំឱ្យអង្គបុរេជំនុំជម្រះពន្យារការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ រហូតដល់បញ្ហាដូចខាងក្រោម ដែលលេចចេញពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី៩ និងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ បានបំភ្លឺរួចរាល់សិន[២៤]៖

ក. តើយើងត្រូវការព័ត៌មានបន្ថែមអំពីបញ្ហាស្តីពីការកំណត់អត្តសញ្ញាណរបស់លោក Bastin ដែរឬទេ។

ខ. តើយើងត្រូវបានអនុញ្ញាតឱ្យទាក់ទាក់ជាមួយនឹងសមាជិកទាំងឡាយរបស់ ក.ស.ច.ស ហើយអាចស្នើសុំពួកគេឱ្យផ្តល់សេចក្តីថ្លែងអះអាងបានដែរឬទេ។

១២. សហមេធាវីការពារក្តី អៀង សារី បានលើកឡើងថា ពួកគេចូលរួមក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ "ដោយសូមរួមបញ្ចូលគ្រប់ទឡ្ហីករណ៍ទាំងអង្គច្បាប់ និងអង្គហេតុដូចមាននៅក្នុងបណ្តឹងនោះ"។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី បានដាក់ជូននូវទឡ្ហីករណ៍បន្ថែមដូចខាងក្រោម ហើយបានផ្អែកលើសេចក្តីថ្លែងការណ៍របស់លោក Bastin ដែរ។

---

[២៣] សេចក្តីស្នើសុំបន្ថែមរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី៧ និងឯកសារលេខ ៦.១ (ERN 00៤១៤២១៥-00៤១៤២១៥) ឯកសារលេខ ៦.២ (ERN 00៤១៤២១៣-00៤១៤២១៨) និងឯកសារលេខ ៦.៣ (ERN 00៤១៧២៥៩-00៤១៧២៦១)។

[២៤] សាលដីកាលើពាក្យបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ រឿងក្តីលេខ ០០២/០៩-១០-២០០៩-អវតក/អបជ(០១) ឯកសារលេខ ៧ ERN 00៤០៧៧១៦-00៤០៧៧២៤ ("សាលដីកាលើកទីមួយលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី តាមវិធាន ៣៤") និងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ រឿងក្តីលេខ ០០២/១៣-១០-២០០៩-អវតក/អបជ(០២) ឯកសារលេខ ៧ ERN 00៤១៤០៩៨-00៤១៤១១០ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន តាមវិធាន ៣៤")។

00533237



យោងតាមសហមេធាវីការពារក្តី សេចក្តីថ្លែងការណ៍នេះបានលាតត្រដាងនូវ "ចង្កោមនូវកិរិយាមិនត្រឹមត្រូវរបស់តុលាការ និងភាពមិនប្រក្រតីនៃការស៊ើបសួរដែលទាក់ទងដល់ចៅក្រម Lemonde"៖

ក. មានបញ្ហារឿងវិធីសាស្ត្រទាក់ទងនឹងចម្លើយសាក្សី និងការធ្វើសង្ខេប ដោយសារអ្នកធ្វើលេខកូដទិន្នន័យ ឬអ្នកវិភាគនៅក្នុង ក.ស.ច.ស មិនមានសិទ្ធិទទួលបាននូវការថតសម្លេងនៃការសម្ភាសន៍សាក្សីឡើយ។ ហេតុដូច្នេះ ពួកគេមិនអាចមានលទ្ធភាពដើម្បីត្រួតពិនិត្យថាតើកំណត់ហេតុស្តាប់ចម្លើយនោះបង្ហាញសុក្រិតភាពដែរឬអត់។ អ្នកធ្វើលេខកូដទិន្និន័យ/អ្នកវិភាគ នឹងបកប្រែនិងធ្វើសេចក្តីសង្ខេបនៃកំណត់ហេតុស្តាប់ចម្លើយដែលពួកគេទទួលបាន ថ្វីបើពួកគេមិនមានគុណវុឌ្ឍិផ្នែកច្បាប់ ឬខាងការបកប្រែក៏ដោយ[២៥]។

ខ. ចៅក្រម Lemonde បានចេញដីកាបង្គាប់ថា "គ្រប់បុគ្គលិកទាំងអស់អាចមានសិទ្ធិចូលមើលប្រព័ន្ធទិន្នន័យនៃសាក្សីផ្ទៃក្នុង ដែលគួរតែបានប្រគល់ឱ្យបុគ្គលិកទាំងឡាយណាដែលបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍សមរម្យ"[២៦]។

១៣. សហមេធាវីការពារក្តី អៀង សារី បានសន្និដ្ឋានថា បណ្តឹងជំទាស់លើកទីពីរ តាមវិធានផ្ទៃក្នុង ៣៤ មានលក្ខណៈចាំបាច់ ដោយហេតុថា លោក Bastin បានផ្តល់មកឱ្យមេធាវីការពារក្តីនូវសេចក្តីថ្លែងការណ៍មួយបន្ថែមទៀតនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ពោលគឺក្រោយពេលអង្គបុរេជំនុំជម្រះបានចេញសេចក្តីជូនដំណឹងអំពីការចេញសាលដីកាលើបណ្តឹងលើកទីមួយរបស់ខ្លួន[២៧]។ បណ្តឹងជំទាស់របស់ អៀង សារី បានរៀបរាប់នូវ "អង្គហេតុថ្មីៗដែលទើបបានរកឃើញ" ប៉ុន្តែបានផ្តោតការផ្តល់ទឡ្ហីករណ៍របស់ខ្លួនជាចំបងលើការចោទប្រកាន់អំពីការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង*រវាងចៅក្រម Lemonde ជាមួយ ក.ស.ព នៅអំឡុងចុងឆ្នាំ២០០៨[២៨]។

---

[២៥] បណ្តឹងជំទាស់របស់ អៀង សារី កថាខណ្ឌទី១ (ក)។

[២៦] បណ្តឹងជំទាស់របស់ អៀង សារី កថាខណ្ឌទី១ (ឃ)។

[២៧] បណ្តឹងជំទាស់របស់ អៀង សារី ទំព័រទី១។

[២៨] បណ្តឹងជំទាស់របស់ អៀង សារី កថាខណ្ឌទី១៣-២៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00533238



១៤. យោងតាមសេចក្តីបន្ថែមរបស់ខ្លួន សហមេធាវីការពារក្តី អៀង សារី ក៏បានផ្តល់កំណត់ត្រាសរសេរដោយដៃរបស់លោក Bastin ហើយបានស្នើសុំឱ្យយកកំណត់ត្រាទាំងនេះមកពិចារណារួមជាមួយនឹងឯកសារផ្សេងទៀតដែលបានផ្តល់ជូននៅក្នុងបណ្តឹងជំទាស់[២៩]។

១៥. សហមេធាវីការពារក្តី នួន ជា យល់ស្របទាំងស្រុងជាមួយនឹងបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ ហើយបានផ្តល់ទឡ្ហីករណ៍បន្ថែមលើការចោទប្រកាន់អំពីភាពលម្អៀងទៅរកផ្នែកអន្តរជាតិនៃ ក.ស.ច.ស ដោយកត់សម្គាល់ថា ចៅក្រម Lemonde ទំនងជាកំពុងធ្វើសកម្មភាពដោយឯកត្តោភាគី ពាក់ព័ន្ធនឹងកិច្ចការរបស់ ក.ស.ច.ស ក្នុងកិច្ចខិតខំយកសក្ខីកម្មពី[redacted][៣០]។ សហមេធាវីការពារក្តីក៏បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ សួរដេញដោលនាពេលសវនាការផ្ទាល់មាត់លើបុគ្គលទាំងឡាយ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនាខែសីហា ឆ្នាំ២០០៩ និងសមាជិកក្រុមថតខ្សែភាពយន្តបារាំងផងដែរ[៣១]។ សហមេធាវីការពារក្តីបានស្នើសុំបន្ថែមដល់អង្គបុរេជំនុំជម្រះរកឱ្យបាននូវកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរមួយច្បាប់ ដែលបានធ្វើឡើងរវាងក្រុមអ្នកថតខ្សែភាពយន្តបារាំង និង ក.ស.ច.ស ហើយបង្គាប់ឱ្យរឹបអូសយកខ្សែអាត់រូបភាពវីដេអូ និង/ឬសម្លេងទាំងអស់ដែលក្រុមអ្នកថតខ្សែភាពយន្តបានថតរួច ស្របតាមកិច្ចព្រមព្រៀងនេះ ដើម្បី "ជួយដល់ អ.ប.ជ ក្នុងការសម្រេចរបស់ខ្លួនលើបណ្តឹងជំទាស់"[៣២]។

១៦. ជនត្រូវចោទទាំងបីបានស្នើសុំយ៉ាងជាក់លាក់[៣៣] ឬដោយប្រយោល[៣៤] ឱ្យបើកសវនាការជាសាធារណៈលើបណ្តឹងជំទាស់របស់ខ្លួន ។

១៧. សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានឆ្លើយតបចំពោះការចោទប្រកាន់នីមួយៗថា៖

[២៩] សេចក្តីបន្ថែមរបស់ អៀង សារី កថាខណ្ឌទី៧។

[៣០] សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា កថាខណ្ឌទី២ *លេខយោង ដូចខាងក្រោម* កថាខណ្ឌទី៧ (ខ)។

[៣១] សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា កថាខណ្ឌទី៣ *លេខយោង ដូចខាងក្រោម* កថាខណ្ឌទី៧ (ឆ)។

[៣២] សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា កថាខណ្ឌទី៤។

[៣៣] បណ្តឹងជំទាស់របស់ អៀង សារី កថាខណ្ឌទី២៦-៣២។ បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៥៥-៥៦។

[៣៤] សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា កថាខណ្ឌទី៣។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ក. ការចោទប្រកាន់ចំពោះភាពមិនប្រក្រតីនៃការស៊ើបអង្កេត ដែលកើតចេញពីកង្វះនៃចំណេះដឹងផ្នែកភាសា មិនមានយុត្តិកម្មចំពោះការប្តឹងជំទាស់ចៅក្រមឡើយ ពីព្រោះវាមិនបានបង្ហាញឱ្យឃើញអំពីភាពលម្អៀងពិតប្រាកដ ឬអាការៈទំនងជាមានភាពលម្អៀងក្នុងការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទេ[៣៥]។

ខ. យើងមិនឃើញមានអង្គហេតុគាំទ្រដល់ការចោទប្រកាន់ថាមានការប្រាស្រ័យទាក់ទងគ្នាពីភាគីតែម្ខាងរវាង ក.ស.ច.ស និង ក.ស.ព[៣៦]។

គ. សេចក្តីថ្លែងការណ៍ជាសាធារណៈរួមគ្នារបស់សហចៅក្រមស៊ើបអង្កេត អំពីការថតខ្សែភាពយន្តលើផ្នែកសម្ងាត់នៃកិច្ចស៊ើបសួរ ដែលថតដោយក្រុមថតខ្សែភាពយន្តបារាំង បានបង្ហាញផ្ទុយពីការចោទប្រកាន់នៅក្នុងបណ្តឹងជំទាស់របស់ អៀង សារី និង អៀង ធីរិទ្ធ យ៉ាងច្បាស់ថា វាហាក់ដូចជាមិនឃើញមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិទេ[៣៧]។

ឃ. យោងតាមការលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរត្រូវបានជំទាស់ ដោយហេតុថាខ្លួនបានផ្តល់ការអនុញ្ញាតឱ្យបុគ្គលិក ដែលមិនបានបណ្តុះបណ្តាលពិនិត្យមើលទិន្នន័យសាក្សីសំខាន់ៗ ការលើកឡើងនេះមិនបានបង្ហាញអំពីលម្អៀងសត្យានុម័ត ឬអត្តនោម័តឡើយ[៣៨]។

ង. ចំពោះការចោទប្រកាន់ទាក់ទងនឹងការប៉ុនប៉ងឱ្យមានឥទ្ធិពលលើការវាយតម្លៃសកម្មភាពការងាររបស់មន្ត្រីជាប់កិច្ចសន្យា សហមេធាវីការពារក្តីជនត្រូវចោទមិនបានបង្ហាញអំពីភាពលម្អៀងសត្យានុម័ត ឬអត្តនោម័តរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលចៅក្រមរូបនេះបានអនុវត្តសិទ្ធិ និងភារកិច្ចរបស់ខ្លួន ក្នុងនាមជាមន្ត្រីរាយការណ៍ទីពីរនៃមន្ត្រីជាប់កិច្ចសន្យា ដើម្បីផ្តល់នូវការវាយតម្លៃសកម្មភាពការងារមន្ត្រីជាប់កិច្ចសន្យា[៣៩]។

ច. ចំពោះការលាក់ទុកព័ត៌មានពី "ផ្នែកកម្ពុជា" របស់ ក.ស.ច.ស អ្នកដាក់ពាក្យបណ្តឹងមិនបានលើកឡើងអំពីថាតើការលាក់ទុកព័ត៌មានបែបនេះធ្វើឱ្យមានភាពលម្អៀងជាក់ស្តែង ឬអាការៈទំនងជាមានភាពលម្អៀងទៅខាង ក.ស.ព ឡើយ ហើយសហចៅក្រមជាតិមិនដែលបានបង្ហាញការមិនសុខចិត្តលើចំនុចនេះដែរ[៤០]។

ឆ. ការចោទប្រកាន់ដែលបានផ្អែកលើសេចក្តីអះអាងមិនត្រឹមត្រូវរបស់ចៅក្រម Lemonde ថាជាច្បាប់ នៅក្នុង "ដីកាសម្រេចលើសំណើសុំឱ្យមានកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅ

---

[៣៥] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៩-២០។

[៣៦] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី២១-២៣។

[៣៧] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី២៤-២៧។

[៣៨] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី២៨-២៩។

[៣៩] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣០-៣២។

[៤០] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣៣-៣៥។

ក្នុងឃ្លាំងផ្ទុកឯកសាររួម"[៤១] និងលើភាពស្ទាក់ស្ទើររបស់គាត់ក្នុងការចង្អុលបង្ហាញឱ្យបានត្រឹមត្រូវចំពោះភស្តុតាងដោះបន្ទុកនៅក្នុងដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន[៤២] គួរត្រូវបដិសេធចោល។ សេចក្តីសម្រេចទាំងនេះមិនបានបង្ហាញភាពលម្អៀងជាសត្យានុម័ត ឬអត្តនោម័តឡើយ ហើយប្រសិនបើសេចក្តីសម្រេចទាំងនេះមានកំហុស សេចក្តីសម្រេចទាំងនេះបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ទាំងកាលពីលើកមុន និងពេលបច្ចុប្បន្ន ក្នុងករណីដែលភាពលម្អៀងនេះមិនបានលើកឡើង។ ទោះក្នុងករណីណាក៏ដោយ ការពិនិត្យសេចក្តីសម្រេចរបស់តុលាការឡើងវិញ ចំពោះបរិបទនៃការចោទប្រកាន់អំពីភាពលម្អៀង មិនមែនមានគោលបំណងស្វែងរកកំហុសណាមួយឡើយ ប៉ុន្តែវាមានគោលបំណងដើម្បីសម្រេចថាតើកំហុសបែបនោះបានបង្ហាញថា ចៅក្រមពិតជា ឬទំនងជាមានភាពលម្អៀងដែរឬទេ អ្នកដាក់ពាក្យបណ្តឹងខកខានក្នុងការបង្ហាញថា តើសេចក្តីសម្រេចបានបណ្តាលឱ្យមានភាពលម្អៀងពិតប្រាកដ ឬច្បាស់លាស់ ដើម្បីស្នើសុំជំទាស់ចៅក្រមបាននោះទេ[៤៣]។

ជ. អ្នកដាក់ពាក្យបណ្តឹង បានផ្អែកទឡ្ហីករណ៍របស់ខ្លួនលើសេចក្តីប្រកាសព័ត៌មានដែលខ្លួនបានចោទប្រកាន់ថា បានបង្ហាញអំពីភាពលម្អៀងរបស់ចៅក្រម Lemonde ទៅខាងសហព្រះរាជអាជ្ញា។ ទឡ្ហីករណ៍នេះបានដាក់ចូលក្នុងបណ្តឹងរួចហើយ ហើយត្រូវបានអង្គបុរេជំនុំជម្រះសម្រេចនៅក្នុងសាលដីការបស់ខ្លួន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩។

១៨. សហព្រះរាជអាជ្ញាបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យច្រានចោលបណ្តឹងជំទាស់ទាំងនេះទុកជាឥតបានការ ដោយហេតុថាបណ្តឹងជំទាស់ទាំងនេះបានដកស្រង់តែភស្តុតាងតិចតួចតែប៉ុណ្ណោះដើម្បីយកមកបដិសេធលើសច្ចធារណ៍នៃអនាគតិរបស់ចៅក្រម ហើយបានលើកទឡ្ហីករណ៍ដដែលៗ ដែលអង្គបុរេជំនុំជម្រះបានលើកឡើង និងច្រានចោលរួចហើយ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានទៀតថា បណ្តឹងជំទាស់លើកឡើងតាមការគិតស្មានថា ក.ស.ច.ស "ផ្នែកជាតិ និងអន្តរជាតិ" មិនមានការប្រាស្រ័យទាក់ទងគ្នា ដែលក្នុងករណីណាក៏ដោយ ករណីនេះនឹងបើកឱ្យយកមកដោះស្រាយតាមនីតិវិធីនៃការខ្វែងយោបល់គ្នាដូចមានចែងនៅក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង[៤៤]។

---

[៤១] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៤ (i)។

[៤២] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៤ (ii)។

[៤៣] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣៦-៣៩។

[៤៤] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី២។

00533241



១៩. យោងតាមសហព្រះរាជអាជ្ញា បញ្ហានេះមិនចាំបាច់ទាមទារឱ្យមានការបើកសវនាការដេញដោលផ្ទាល់មាត់ឡើយ[៤៥]។

២០. អង្គបុរេជំនុំជម្រះពិចារណាឃើញថា សហព្រះរាជអាជ្ញាមិនមានសិទ្ធិនៅក្នុងប្រភេទបណ្តឹងបែបនេះឡើយ។ ប៉ុន្តែ ប្រសិនបើអង្គបុរេជំនុំជម្រះពិចារណាឃើញថា សហព្រះរាជអាជ្ញាអាចជាភាគីដែលមានប្រយោជន៍ សហព្រះរាជអាជ្ញាអាចចូលរួម ឬអាចត្រូវបានអញ្ជើញឱ្យជួយផ្តល់ជាយោបល់ ឬដាក់សេចក្តីសន្និដ្ឋាននៅក្នុងរឿងក្តីទាំងឡាយ ដែលអង្គបុរេជំនុំជម្រះយល់ឃើញថា សមស្របក្នុងការអនុញ្ញាតឱ្យដាក់សេចក្តីសន្និដ្ឋាន។ អង្គបុរេជំនុំជម្រះយល់ឃើញថា សហព្រះរាជអាជ្ញាអាចជួយនៅក្នុងរឿងក្តីនេះបាន ហេតុដូច្នេះ អង្គបុរេជំនុំជម្រះទទួលយកការឆ្លើយតបរបស់សហព្រះរាជអាជ្ញា។

## III. ភាពអាចទទួលយកបាននៃបណ្តឹងជំទាស់

២១. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងជំទាស់មានចែងនៅក្នុងវិធាន ៣៤(២) នៃវិធានផ្ទៃក្នុងថា៖

> "ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពលម្អៀង។"

២២. វិធាន ៣៤(៥) នៃវិធានផ្ទៃក្នុងចែងនៅក្នុងបទប្បញ្ញត្តិដែលពាក់ព័ន្ធថា "ពាក្យបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជូនទៅអង្គបុរេជំនុំជម្រះ"។ នៅពេលពិចារណាវិធានទាំងពីរនេះរួមគ្នា អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនមានយុត្តាធិការពិចារណាលើបណ្តឹងជំទាស់។

[៤៥] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣-៩។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

២៣. កាតព្វកិច្ចរបស់ភាគីដែលដាក់បណ្តឹងជំទាស់ទៅក្រុមណាមួយ ត្រូវបានបញ្ញត្តិនៅក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុងថា៖

"ភាគីដែលធ្វើបណ្តឹងជំទាស់ ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និង ត្រូវមានភស្តុតាងបញ្ជាក់ផងដែរ។ ពាក្យបណ្តឹងត្រូវធ្វើឡើងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ"។

២៤. សេចក្តីថ្លែងការណ៍ដែលបណ្តឹងជំទាស់យកមកធ្វើជាមូលដ្ឋាន បានផ្តល់ជូនដល់អ្នកដាក់បណ្តឹងដោយលោក Bastin នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ("សេចក្តីថ្លែងការណ៍លើកទីពីររបស់លោក Bastin")។ សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានសន្និដ្ឋានថា ខ្លួនបានចាប់ផ្តើមរៀបចំបណ្តឹងនេះដោយឥតបង្អង់ឡើយ ក្រោយពីពេលដែលខ្លួនបានទទួលសេចក្តីថ្លែងការណ៍លើកទីពីររបស់លោក Bastin[៤៦]។ សហមេធាវីការពារក្តី អៀង សារី បានសន្និដ្ឋានថា នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ខ្លួនបានព្យាយាមជូនដំណឹងជាមុនដល់អង្គបុរេជំនុំជម្រះអំពីអង្គហេតុបន្ថែម ដែលលោក Bastin បានផ្តល់ជូន[៤៧]។

២៥. បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ បានដាក់ប្តឹងនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ហើយបណ្តឹងជំទាស់របស់ អៀង សារី បានដាក់ប្តឹងនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩។ សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា បានដាក់នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា សហមេធាវីការពារក្តីជនត្រូវចោទបានដាក់បណ្តឹងភ្លាមៗ ក្រោយពីខ្លួនបានដឹងអំពីមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋាននៃបណ្តឹងដទៃទៀត។ ដោយយោងលើករណីនេះ បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ បណ្តឹងជំទាស់របស់ អៀង សារី និង សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា បានដាក់ទាន់ពេលកំណត់ ដូចមានចែងនៅក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង។ ដោយហេតុថា ដីកាដំណោះស្រាយមិនទាន់ចេញនៅឡើយ បណ្តឹងជំទាស់ទាំងនេះក៏បានដាក់ទាន់ពេលកំណត់ផងដែរ អនុលោមតាមវិធាន ៣៤(៤)(ក) នៃវិធានផ្ទៃក្នុង។

[៤៦] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌទី១៧។

[៤៧] បណ្តឹងជំទាស់របស់ អៀង សារី ទំព័រទី១។

## IV. សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍

### ក. សំណើរបស់ អៀង ធីរិទ្ធ សុំពន្យារការពិចារណាលើបណ្តឹងជំទាស់

២៦. សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះពន្យារការពិចារណាលើបណ្តឹងជំទាស់របស់ខ្លួន រហូតដល់ពេលខ្លួនទទួលបានការឆ្លើយបញ្ជាក់ជាមុនសិនថាតើចាំបាច់ត្រូវការព័ត៌មានបន្ថែមលើបញ្ហាកំណត់អត្តសញ្ញាណរបស់លោក Bastin ដែរឬយ៉ាងណា ហើយថាតើគេអនុញ្ញាតឱ្យទាក់ទងសមាជិកនៅក្នុង ក.ស.ច.ស ដើម្បីសុំឱ្យផ្តល់ចម្លើយលើបណ្តឹងជំទាស់ដែរឬទេ។

២៧. អនុលោមតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ភាគីដែលដាក់បណ្តឹងជំទាស់ទៅក្រុម ត្រូវផ្តល់ភស្តុតាងគាំទ្រ។ ការចោទប្រកាន់អំពីភាពលម្អៀងត្រូវតែមានមូលដ្ឋានអង្គហេតុយកមកគាំទ្រ ហើយភាគីដាក់បណ្តឹងត្រូវផ្តល់ឯកសារសម្ភារៈដែលពាក់ព័ន្ធដើម្បីធ្វើជាមូលដ្ឋាន។ សហមេធាវីការពារក្តីព្រួយបារម្ភថា បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ នឹងត្រូវបដិសេធចោល "ដោយសារមូលហេតុដែលត្រូវបានចាត់ទុកថាមានភាពមិនគ្រប់គ្រាន់ខាងនីតិវិធី ឬកង្វះនូវភស្តុតាងបញ្ជាក់បន្ថែម ដែលអាចរកបាន"[៤៨]។

២៨. កាលពីលើកមុន អង្គបុរេជំនុំជម្រះបានរកឃើញថា ភស្តុតាងនានាមិនបានបង្ហាញឱ្យបានគ្រប់គ្រាន់ដោយសារហេតុផលជាច្រើន។ ភាគីដាក់បណ្តឹងត្រូវសម្រេចថាតើខ្លួនត្រូវជ្រើសរើសយកនីតិវិធីណាមួយដើម្បីទទួលបានភស្តុតាង ដែលអាច "ទទួលបាន" ដើម្បីយកមកធ្វើជាមូលដ្ឋាននៃបណ្តឹងជំទាស់ ហើយភាគីដាក់បណ្តឹងត្រូវធ្វើការសន្និដ្ឋានពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងត្រូវផ្តល់ភស្តុតាងដែលអង្គបុរេជំនុំជម្រះត្រូវការ។ ដូច្នេះ សំណើនេះត្រូវបានបដិសេធចោលចាត់ទុកជាឥតបានការ។

---

[៤៨] សេចក្តីស្នើសុំបន្ថែមរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី៦។

00533244



ខ. សំណើសុំបើកសវនាការសាធារណៈ

២៩. សហមេធាវីការពារក្ដី អៀង ធីរិទ្ធ បានសន្និដ្ឋានថា សវនាការដេញដោលផ្ទាល់មាត់នឹងផ្ដល់ឱកាសដល់ភាគី ធ្វើការឆ្លើយតបទៅនឹងអង្គហេតុនានាដែលបានចោទប្រកាន់នៅក្នុងបណ្ដឹងជិតចិត្ត ហើយនឹងធានានូវតម្លាភាពនៃកិច្ចដំណើរការនីតិវិធី[៤៩]។

៣០. យោងតាមបណ្ដឹងជិតចិត្តរបស់ អៀង សារី សហមេធាវីការពារក្ដីបានលើកឡើងថា "សវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ជាមួយនឹងការស្ដាប់ចម្លើយជាកស្សិណរបស់បុគ្គលដែលពាក់ព័ន្ធទាំងអស់ គឺមានសារៈសំខាន់ ដើម្បីអនុញ្ញាតឱ្យសាធារណៈជនធ្វើការពិនិត្យពិច្ឆ័យទៅលើបញ្ហានេះ និងដើម្បីការពារសុចរិតភាព និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី"។ យោងតាមសហមេធាវីការពារក្ដី វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង មិនបានចែងថា រាល់ភស្ដុតាងគាំទ្រត្រូវតែដាក់នៅពេលជាមួយគ្នាជាមួយនឹងការដាក់ពាក្យបណ្ដឹងនោះឡើយ ហើយរឿងដែលថា វិធាន ៣៤(៧) នៃវិធានផ្ទៃក្នុងមិនមានចែងឱ្យបានច្បាស់លាស់អំពីសវនាការដេញដោលផ្ទាល់មាត់ មិនមែនមានន័យថា លទ្ធភាពឱ្យមានសវនាការដេញដោលផ្ទាល់មាត់មួយ មិនត្រូវបានអនុញ្ញាតតាមវិធានផ្ទៃក្នុងឡើយ[៥០]។ ដោយយល់ឃើញថា អង្គបុរេជំនុំជម្រះបានពិចារណាកាលពីលើកមុនថា ភស្ដុតាងដែលគាំទ្របណ្ដឹងជិតចិត្តលើកទីមួយ ដែលបានប្ដឹងផ្អែកតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង មិនមានលក្ខណៈ "រឹងប៉ឹង" ឡើយ នៅពេលដែលអង្គបុរេជំនុំជម្រះនេះធ្វើការពិចារណាថា សេចក្ដីថ្លែងការណ៍លើកទីមួយរបស់លោក Bastin ជាភស្ដុតាងតែមួយគត់ដែលបានផ្ដល់ជូន សហមេធាវីការពារក្ដី អៀង សារី បានអះអាងថា សវនាការដេញដោលផ្ទាល់មាត់មួយ "ត្រូវតែគេបានគេអនុញ្ញាតជាដាច់ខាត"[៥១]។

៣១. យោងតាមសេចក្ដីជូនដំណឹងអំពីបណ្ដឹងរួមរបស់ នួន ជា សហមេធាវីការពារក្ដីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ សួរដេញដោលបុគ្គលមួយចំនួនក្នុងសវនាការផ្ទាល់មាត់ ដោយហេតុថា

---

[៤៩] បណ្ដឹងជិតចិត្តរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី៥៥-៥៦។

[៥០] បណ្ដឹងជិតចិត្តរបស់ អៀង សារី កថាខណ្ឌទី២៦។

[៥១] បណ្ដឹងជិតចិត្តរបស់ អៀង សារី កថាខណ្ឌទី២៧។

00533245



"សក្ខីកម្មរបស់អ្នកទាំងនេះ មានសារៈសំខាន់ខ្លាំងដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវចំពោះបញ្ហាទាំងឡាយ ដូចដែលបានលើកឡើងនៅក្នុងបណ្តឹង" [៥២]។

៣២. អង្គបុរេជំនុំជម្រះបានរកឃើញនាពេលមុនថា នីតិវិធីដែលបានចែងនៅក្នុងវិធាន ៣៤(៧) នៃវិធានផ្ទៃក្នុងកំណត់ថា អង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដោយមិនបានកំណត់អំពីសវនាការឡើយ [៥៣]។ បន្ថែមលើចំណុចនេះ យោងតាមលក្ខខណ្ឌនៅក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ភស្តុតាងគាំទ្រទាំងអស់ត្រូវដាក់ភ្ជាប់មក*ជាមួយ*នឹងបណ្តឹងជំទាស់ ហើយបន្ទុកក្នុងការបង្ហាញភស្តុតាងច្រានចោលសច្ចធារណ៍នៃអនាគតិរបស់ចៅក្រម ជាបន្ទុករបស់អ្នកដាក់បណ្តឹងទាំងស្រុង និងអាស្រ័យលើភស្តុតាងដែលត្រូវបង្ហាញ*នៅពេល*ដាក់បណ្តឹង [៥៤]។

៣៣. អង្គបុរេជំនុំជម្រះក៏បានសម្រេចនាពេលមុនផងដែរថា ក្នុងករណីអង្គបុរេជំនុំជម្រះមានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចលើបណ្តឹង ហើយក្នុងករណីដែលវាជាផលប្រយោជន៍យុត្តិធម៌ក្នុងការបន្តកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស អង្គបុរេជំនុំជម្រះអាចធ្វើការវិនិច្ឆ័យលើបញ្ហានេះ ដោយមិនចាំបាច់បើកសវនាការជាសាធារណៈ [៥៥]។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

---

[៥២] សេចក្តីជូនដំណឹងអំពីបណ្តឹងរួមរបស់ នួន ជា កថាខណ្ឌទី៣។

[៥៣] សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការសមរម្យពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើឡើងដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រម Katinka Lahuis និងចៅក្រម Rowan Downing ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ រឿងក្តីលេខ ០០២/២០-១០-២០០៩-អវតក/អបជ(០៣) ឯកសារលេខ ៥ ERN ០០៤០៤៥៩៥-០០៤០៤៦០១ កថាខណ្ឌទី២។

[៥៤] សាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ រឿងក្តីលេខ ០០២/១៣-១០-២០០៩-អវតក/អបជ(០២) ឯកសារលេខ ៧ ERN ០០៤១៤០៩៨-០០៤១៤១១០ កថាខណ្ឌទី២២។

[៥៥] សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល រង់ចាំបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើរឿងក្តី នួន ជា រឿងក្តីលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១) ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ C11/29 ("សាលដីកាលើចៅក្រម ន័យ ថុល") កថាខណ្ឌទី ៨ ដូចលេខយោងខាងក្រោម។ វិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុងផ្តល់អំណាចដល់អង្គជំនុំជម្រះ

៣៤. អង្គបុរេជំនុំជម្រះយល់ឃើញដូចនាពេលមុនថា តម្លាភាពនៃកិច្ចដំណើរការនីតិវិធីនឹងត្រូវបានធានាតាមរយៈការចាត់ចំណាត់ថ្នាក់សារជាថ្មីលើការដាក់ឯកសារទាំងអស់ ដែលពាក់ព័ន្ធនឹងបណ្តឹងទាំងនេះថាជាឯកសារសាធារណៈ[៥៦]។

៣៥. ផ្ទុយពីការអះអាងរបស់សហមេធាវីការពារក្តី ភស្តុតាងគាំទ្រត្រូវតែផ្តល់ជូននៅពេលដាក់បណ្តឹង ហើយសហមេធាវីការពារក្តីមានបន្ទុកក្នុងការបង្ហាញភស្តុតាងចំពោះការចោទប្រកាន់អំពីភាពលម្អៀង។ អង្គជំនុំជម្រះដែលបានទទួលបណ្តឹងមិនមានកាតព្វកិច្ចបើកសវនាការជាសាធារណៈដើម្បីធ្វើការស៊ើបអង្កេតជំនួសអ្នកដាក់បណ្តឹង ឬបើកសវនាការដើម្បីប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់បណ្តឹងរបស់ភាគីឡើយ។ ដោយសារតែអង្គបុរេជំនុំជម្រះមិនមានកាតព្វកិច្ចស៊ើបអង្កេត ឬប្រមូលភស្តុតាងឱ្យអ្នកដាក់បណ្តឹង អង្គបុរេជំនុំជម្រះបដិសេធចោលលើសំណើសុំបើកសវនាការដេញដោលផ្ទាល់មាត់។

## គ. សំណើជិតចិត្តចំពោះចៅក្រម

៣៦. អង្គបុរេជំនុំជម្រះ បានថែងអំពីច្បាប់ស្តីពីបណ្តឹងជិតចិត្តចំពោះចៅក្រម នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនឹងពាក្យសុំជិតចិត្តចំពោះចៅក្រម ន័យ ធុល ("សាលដីកាលើចៅក្រម ន័យ ធុល")[៥៧]។ បទដ្ឋានសម្រាប់វាយតម្លៃភាពលម្អៀង ដែលអាចយកមកអនុវត្តបាន មានចែងនៅក្នុងវិធាន ៣៤(២) នៃវិធានផ្ទៃក្នុង ដោយរៀបរាប់ទាំងភាពលម្អៀងជាក់ស្តែង និងភាពលម្អៀងតាមការយល់ឃើញ។

---

សម្រេចលើបណ្តឹង ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ ចំពោះបណ្តឹងឧទ្ធរណ៍ និងពាក្យសុំឡាយណា ដែលធ្វើឡើងអនុលោមតាមអនុវិធាន ៧៣ (ក)-(គ) នៃវិធានផ្ទៃក្នុង។

[៥៦] សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការសមរម្យពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើឡើងដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះចៅក្រម Katinka Lahuis និងចៅក្រម Rowan Downing ០០២/២០-១០-២០០៩-អវតក/អបជ (០៣) ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ រឿងក្តីលេខ ឯកសារលេខ ៥ ERN ០០៤០៤៥៩៥-០០៤០៤៦០១ កថាខណ្ឌទី២។

[៥៧] សូមប្រៀបធៀបសាលដីកាលើចៅក្រម *ន័យ ធុល*។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

៣៧. ពីកថាខណ្ឌ១៥ ដល់កថាខណ្ឌ២១ នៃសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ដែលមានក្នុងសាលដីកាលើចៅក្រម ន័យ ថុល (ដោយលប់ចោលនូវជើងទំព័រ) រៀបរាប់ដូចខាងក្រោម៖

*១៥. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា "ចំណុចចាប់ផ្ដើមនៃការសម្រេចលើការជំទាស់អំពី [ភាពលម្អៀង] គឺថា "មានការសន្មតទុកជាមុនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម"។ "ការសន្មតនេះ កើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងរបស់គាត់ [...]" និងដាក់បន្ទុកដ៏ធ្ងន់ចំពោះភាគីដែលធ្វើបណ្ដឹងជំទាស់ក្នុងការដកចេញនូវការសន្មតទុកជាមុននេះ"។*

*១៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ការសន្មតអំពីភាពអនាគតិនេះ គឺអនុវត្តចំពោះចៅក្រមទាំងអស់នៅ អ.វ.ត.ក។ មាត្រា ៣.៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ចែងថា៖*

> *ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត មានគុណសម្បត្តិដែលតម្រូវសម្រាប់តែងតាំងឲ្យបម្រើការងារក្នុងការិយាល័យតុលាការ នៅក្នុងប្រទេសរបស់ខ្លួន។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ។*

*តាមមាត្រា ៧.២ នៃកិច្ចព្រមព្រៀង បទប្បញ្ញត្តិនេះត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ។*

*១៧. មាត្រា ១០ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា "ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញត្រូវតែងតាំងចេញពីក្នុងចំណោមចៅក្រមដែលកំពុងបំពេញការងារបច្ចុប្បន្ន ឬទទួលការតែងតាំងបន្ថែមយោងតាមនីតិវិធីដែលមានស្រាប់សម្រាប់ការតែងតាំងនេះ ចៅក្រមទាំងអស់ត្រូវមានចរិតលក្ខណៈសីលធម៌ខ្ពស់ ស្មារតីអនាគតិ ភាពសុច្ចរិត និងជាពិសេសមានបទពិសោធន៍ ក្នុងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង។ ចៅក្រមទាំងអស់ ត្រូវស្ថិតនៅឯករាជ្យក្នុងការបំពេញមុខនាទីរបស់ខ្លួន និងមិនត្រូវទទួលយក ឬស្វែងរកការណែនាំណាមួយពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយដទៃទៀតឡើយ"។*

*១៨. អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៦ ចៅក្រមនៃអង្គបុរេជំនុំជម្រះ របស់ អ.វ.ត.ក រួមទាំងចៅក្រម ន័យ ថុល ផងដែរ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងបានធ្វើសច្ចាប្រណិធានជាផ្លូវការណ៍ ក្នុងពិធីផ្លូវការណ៍មួយ។*



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00533248



*១៩. ក្នុងបញ្ហានេះ អ្នកប្តឹងជិតចិត្តត្រូវបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ដល់អង្គបុរេជំនុំជម្រះដើម្បីឲ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ចៅក្រមដែលត្រូវបានប្តឹងចោទប្រកាន់នោះអាចមានភាពលម្អៀងពិតប្រាកដមែន។ នៅមានចំណុចជាមូលដ្ឋានជាច្រើនដែលត្រូវបំពេញ ដើម្បីជំទាស់ទៅនឹងសច្ចធារណ៍នៃអនាគតិ។*

*២០. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ គឺមានលក្ខណៈដូចគ្នាក្នុងការធ្វើការវាយតម្លៃអំពីភាពលម្អៀងដែលបានអនុវត្តក្នុងពេលនេះ។ សាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") បានយល់ឃើញក្នុងករណីរបស់ ហ្វូរ៉ាន់ហ្ស៊ីហ្សា (Furundzija) ថា៖*

> *ចៅក្រមមួយរូបត្រូវបានចាត់ទុកថាមានភាពលម្អៀង ប្រសិនបើត្រូវបានរកឃើញថាមានសកម្មភាពលម្អៀងពិតប្រាកដមែន។*
>
> *មានការលម្អៀងតាមរយៈការមើលឃើញពីខាងក្រៅ ប្រសិនបើ៖*
>
> - *ចៅក្រមមួយរូបជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទាក់ទងនឹងកម្មសិទ្ធិ ដែលបានមកពីរឿងក្តីនោះ ឬ ប្រសិនបើការសម្រេចសេចក្តីរបស់ចៅក្រមនឹងនាំឲ្យមានការគាំទ្រដល់រឿងក្តីមួយ ដែលរូបគាត់មានការពាក់ព័ន្ធជាមួយភាគីណាមួយនៃរឿងក្តីនោះ។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះ ត្រូវដកខ្លួនចេញពីរឿងក្តីនោះដោយស្វ័យប្រវត្តិ ឬ*
> - *ក្នុងកាលៈទេសៈដែលអាចនាំឲ្យមានអ្នកកត់សម្គាល់សមហេតុផលណាម្នាក់ ដែលទទួលបានព័ត៌មានត្រឹមត្រូវ យល់ដឹងដោយសមហេតុផលអំពីភាពលម្អៀង។*

*យុត្តិសាស្ត្រនេះត្រូវបានអនុវត្តជាទូទៅដោយតុលាការអន្តរជាតិ។*

*២១. អ្នកកត់សម្គាល់ដ៏សមហេតុផលក្នុងការវាយតម្លៃអំពីភាពលម្អៀងនេះ គឺត្រូវតែជា "បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់ យល់ដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងអនាគតិដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងការវាយតម្លៃអំពីអង្គហេតុផងដែលថា អនាគតិ គឺជាករណីកិច្ចមួយក្នុងចំណោមករណីកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបសច្ចាគាំទ្រលើកតម្កើង"។*

៣៨. ក្រមសីលធម៌ចៅក្រម នៃ អ.វ.ត.ក ចែងបន្ថែមពីសេចក្តីណែនាំអំពីករណីនេះ។ មាត្រា ២.១ ចែងថា "ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលម្អៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន"[៥៨]។ មាត្រា៧.១ ចែងផងដែរថា "ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈណា ដែលសមស្រប

---

[៥៨] ក្រមសីលធម៌ចៅក្រម អនុម័តក្នុងកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងបានធ្វើវិសោធនកម្មនៅក្នុងកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា ២(១)។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

ជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ"[៥៩]។ ក្រមសីលធម៌ចៅក្រមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏មានបទប្បញ្ញត្តិដូចគ្នានេះដែរ[៦០]។

៣៩. មាត្រា២.២ នៃ*គោលការណ៍ក្រមសីលធម៌ចៅក្រម បែងហ្គាល័រ (Bangalore)* ចែងថា ចៅក្រម "ត្រូវធានាថាអាកប្បកិរិយារបស់ខ្លួន ទាំងនៅក្នុងនិងក្រៅតុលាការ រក្សា និងពង្រឹងភាពជឿជាក់របស់សាធារណជន អ្នកប្រកបវិជ្ជាជីវៈច្បាប់ និងភាគីនៃរឿងក្តី ទៅលើអនាគតិរបស់ចៅក្រម និងតុលាការ"[៦១]។ កំណត់សម្គាល់ភ្ជាប់ជាមួយនឹងមាត្រានេះបន្តរៀបរាប់ថា "ចៅក្រមគួរជៀសវាងការប្រើប្រាស់ពាក្យពេចន៍ដោយចេតនា ឬអាកប្បកិរិយា ដែលអាចឱ្យគេយល់ឃើញយ៉ាងសមហេតុផលថា ខ្លួនបាត់បង់អនាគតិ" ហើយថា "កំណត់សម្គាល់ដែលចៅក្រមអាចយល់ឃើញថាជា 'ការនិយាយលេងសើចធម្មតា' អាចធ្វើឱ្យបាត់បង់អនាគតិដែលត្រូវបានសន្មតជាមុនរបស់ចៅក្រមបាន"[៦២]។

### ១. *ភាពលម្អៀងដែលត្រូវបានចោទទៅលើការស្វែងរកភស្តុតាងដាក់បន្ទុកច្រើនជាងភស្តុតាងដោះបន្ទុក៖ ការប្រជុំនៅខែសីហា ឆ្នាំ២០០៩*

៤០. អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយលើការចោទប្រកាន់ស្រដៀងគ្នានេះ ដែលផ្អែកទៅលើសេចក្តីថ្លែងការណ៍របស់លោក Bastin ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៩ និងបានរក

ការិយាល័យរដ្ឋបាលជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C.

[៥៩] *ក្រមសីលធម៌ចៅក្រម* មាត្រា ៧(១)។

[៦០] *ក្រមសីលធម៌ចៅក្រមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ* មាត្រា ៤.១ និង ៩.១ (ICC-BO/D2-01-05)។

[៦១] អនុម័តដោយក្រុមតុលាការលើការពង្រឹងសុច្ចរិតភាពរបស់តុលាការ ដែលត្រូវបានកែតម្រូវនៅក្នុងកិច្ចប្រជុំតុមូលនៃចៅក្រមដែលជាប្រធាន ប្រព្រឹត្តទៅនៅ Peace Palace ទីក្រុងឡាអេ ពីថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០០២។ សម្រាប់ការអនុវត្តគោលការណ៍បែងហ្គាល័រ នៅតុលាការពិសេសសម្រាប់ Sierra Leone សូមមើល "*សេចក្តីសម្រេចលើបណ្តឹងរបស់រដ្ឋអាជ្ញាក្នុងការបង្ហាញភស្តុតាងដូចគ្នាក្នុងពេលតែមួយក្នុងរឿងក្តី SCSL-2004-15-PT និង SCSL-2004-16-PT*"។

[៦២] សេចក្តីអត្ថាធិប្បាយលើគោលការណ៍ក្រមសីលធម៌ចៅក្រម បែងហ្គាល័រ ក្រុមការងារដើម្បីសុច្ចរិតភាពរបស់តុលាការ ខែមីនា ឆ្នាំ២០០៧ កថាខណ្ឌ ៦៥។

00533250



ឃើញថា ភស្តុតាងដែលបានផ្តល់ឱ្យអំពីបញ្ហានេះ មិនមានភាពគ្រប់គ្រាន់ទេ[៦៣]។ ពាក្យបណ្តឹងរបស់ អៀង ធីរិទ្ធ ដែលក្នុងនោះបានលើកឡើងសារជាថ្មីពីភាពលម្អៀងនេះ ក៏ផ្អែកទៅលើសេចក្តីថ្លែងការណ៍លម្អិតលើកទីពីររបស់លោក Bastin ចុះថ្ងៃទី0២ ខែធ្នូ ឆ្នាំ២00៩។

៤១. សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ អះអាងថាសេចក្តីថ្លែងការណ៍របស់លោក Bastin ទាំងពីរលើកនោះ បង្កើតបានជា "មូលដ្ឋានភស្តុតាងបឋម" ដែលខ្លួនយកមកគាំទ្រពាក្យបណ្តឹងរបស់ខ្លួននោះ[៦៤]។ សេចក្តីថ្លែងការណ៍ទីពីររបស់ Bastin មិនបានផ្តល់ព័ត៌មានអ្វីទាក់ទងទៅនឹងការប្រជុំនៅក្នុងខែសីហា ឆ្នាំ២00៩ ទេ។ កំណត់ត្រារបស់លោក Bastin ហាក់ដូចជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីថ្លែងការណ៍ដំបូងរបស់គាត់ នៅក្នុងខែតុលា ឆ្នាំ២00៩។ ការរៀបរាប់តែមួយគត់ពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅពេលប្រជុំ ត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ទីមួយរបស់លោក Bastin ជៀសជាងការរំលឹកឡើងវិញរបស់ចៅក្រម Lemonde។ នៅក្នុងសេចក្តីសម្រេចលើកមុនរបស់ខ្លួន អង្គបុរេជំនុំជម្រះបានចាត់ទុកការរៀបរាប់នេះ ថាជាភស្តុតាងមិនមានភាពគ្រប់គ្រាន់។ ភស្តុតាងដាក់នៅក្នុងពាក្យបណ្តឹងរបស់ អៀង ធីរិទ្ធ មិនបានផ្តល់នូវមូលដ្ឋានអង្គហេតុបន្ថែមណាមួយដើម្បីធ្វើការច្រានចោលនូវសច្ចធារណ៍នៃអនាគតិរបស់ចៅក្រម Lemonde ឡើយ។ ហេតុដូច្នេះ ភស្តុតាងដែលបានបង្ហាញនេះ មិនអាចនាំឱ្យចាត់ទុកបានថា មានភាពលម្អៀង ឬការលេចចេញឱ្យឃើញនូវភាពលម្អៀងរបស់ចៅក្រម Lemonde ដូចបានចោទប្រកាន់នោះទេ។

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C.

---

[៦៣] សេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ អៀង សារី ប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី0៩ ខែធ្នូ ឆ្នាំ២00៩ រឿងក្តីលេខ 00២/0៩-១0-២00៩-អវតក/អបជ(១) ឯកសារលេខ ៧។ សូមមើលផងដែរ សាលដីកាសាធារណៈលើពាក្យបណ្តឹងរបស់ នួន ជា ប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២0១0 រឿងក្តីលេខ 00២/២៩-១0-២00៩-អវតក/អបជ(0៤) កថាខណ្ឌ ១៩ ("សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ នួន ជា")។

[៦៤] ពាក្យបណ្តឹង អៀង ធីរិទ្ធ កថាខណ្ឌ ១១។

## ២. ទំនាក់ទំនងរវាងភាគីតែម្ខាង ដែលត្រូវបានចោទប្រកាន់ថាកើតមានរវាង ក.ស.ព និង ក.ស.ច.ស

៤២. យោងតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក ការចាប់ផ្តើមសម្រេចណាមួយទៅលើការចោទប្រកាន់ថាមានភាពលម្អៀង គឺត្រូវចាប់ផ្តើមពីការសន្មតទុកជាមុនថា ចៅក្រមទាំងអស់នៅ អ.វ.ត.ក គ្មានភាពលម្អៀង ដោយផ្អែកទៅលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែង និងគុណសម្បត្តិសម្រាប់ការតែងតាំងរបស់ចៅក្រម។ សេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin និងកំណត់ត្រាថ្មីៗរបស់សេចក្តីថ្លែងការណ៍នេះ គឺជាភស្តុតាងតែមួយគត់ ដែលត្រូវបានលើកយកមកបង្ហាញដោយសហមេធាវីការពារក្តី ដើម្បីគាំទ្រពាក្យបណ្តឹងរបស់ខ្លួន សុំប្តឹងជំទាស់ចៅក្រម Lemonde។

៤៣. អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ភាគីដែលបានចោទប្រកាន់ថាមានអត្ថិភាពនៃភាពលម្អៀង ត្រូវមានបន្ទុកច្រានចោលនូវការសន្មតទុកជាមុននេះ ដែលលក្ខខណ្ឌតម្រូវមានកម្រិតខ្ពស់ ទាមទារឱ្យភាគីនោះបង្ហាញភស្តុតាងឱ្យគ្រប់គ្រាន់ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន។ សេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin លើកឡើងពីការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរចំពោះចៅក្រម Lemonde។ ប៉ុន្តែ សេចក្តីថ្លែងការណ៍នេះ គឺជាភស្តុ-តាងតែមួយគត់នៅក្នុងពាក្យបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ និងពាក្យបណ្តឹងជំទាស់របស់ អៀង សារី ក្នុងការគាំទ្រការចោទប្រកាន់ថាមានភាពលម្អៀង ប្រឆាំងជនត្រូវចោទ ដោយអនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង។ មិនមានបុគ្គលណាមួយ ដែលត្រូវបានអះអាងថាមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ ឬមានភាពពាក់ព័ន្ធដោយផ្ទាល់ ឬមិនផ្ទាល់ជាមួយនឹងព្រឹត្តិការណ៍ទាំងនោះ ផ្តល់ឱ្យនូវភស្តុតាងគាំទ្រការចោទប្រកាន់នេះឡើយ។

៤៤. អង្គបុរេជំនុំជម្រះ បដិសេធលើសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តីរបស់ អៀង សារី ដែលអះអាងថា វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង មិនបានចែងថា ភស្តុតាងគាំទ្រទាំងអស់ត្រូវតែដាក់ដោយភាគីដាក់ពាក្យបណ្តឹងទេ។ ភាគីដាក់ពាក្យបណ្តឹង អាចដាក់ភស្តុតាងបន្ថែមទៀតនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីគាំទ្រពាក្យបណ្តឹងរបស់ខ្លួនប្រសិនបើភស្តុតាងនោះ អាចរកបានក្រោយពេលដាក់ពាក្យបណ្តឹង។ មិនមានបទប្បញ្ញត្តិ



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

ណាមួយនៅក្នុងវិធានផ្ទៃក្នុង ចែងអំពីមូលដ្ឋាននៃសិទ្ធិ សម្រាប់ឱ្យអង្គបុរេជំនុំជម្រះធ្វើការស្រាវជ្រាវអំពីបញ្ហានៅក្នុងពាក្យបណ្តឹងអនុលោមតាមវិធាន ៣៤ នោះទេ។ ផ្ទុយពីសិទ្ធិក្នុងការស្រាវជ្រាវ ដែលមានចែងនៅក្នុងវិធាន ៣៥.២ នោះ វិធាន ៣៤(៣) ចែងថា ភាគីត្រូវផ្តល់ភស្តុតាងគាំទ្រ សម្រាប់សេចក្តីសម្រេចលើបណ្តឹងនោះ បើអាចរកបានភស្តុ-តាងទាំងអស់កាន់តែប្រសើរ។ ការចោទប្រកាន់ថាមានទំនាក់ទំនងរវាងភាគីតែម្ខាង រវាង ក.ស.ច.ស និង ក.ស.ព ខ្វះមូលដ្ឋានអង្គហេតុ ដើម្បីច្រានចោលការសន្មតទុកជាមុនថា ចៅក្រម Lemonde គ្មានភាពលម្អៀង។ ដូច្នេះ ភស្តុតាងដែលបានផ្តល់ មិនបានបង្ហាញពីភាពលម្អៀង ឬការលេចចេញនូវភាពលម្អៀងរបស់ចៅក្រម Lemonde ដូចដែលបានចោទប្រកាន់នោះទេ។

៣. *សេចក្តីថ្លែងការណ៍មានកំហុស ទាក់ទងនឹងអង្គច្បាប់លើកឡើងនៅក្នុងសាលដីកា SMD*

៤៥. អង្គបុរេជំនុំជម្រះបានរកឃើញរួចមកហើយថា នៅពេលដែលការចោទប្រកាន់លើភាពលម្អៀង ត្រូវបានធ្វើឡើងដោយផ្អែកតាមសេចក្តីសម្រេចរបស់ចៅក្រមណាម្នាក់នោះ ការចោទប្រកាន់ថាមានកំហុសអង្គច្បាប់ ប្រសិនបើមានមែននោះ គឺពុំគ្រប់គ្រាន់ទេ។ ត្រូវមានការបង្ហាញថា សេចក្តីសម្រេចនាំឱ្យមាន ឬអាចត្រូវបានគេយល់ឃើញដោយសមហេតុផលថានាំឱ្យមានបុរេវិនិច្ឆ័យប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹង ហើយសេចក្តីសម្រេចទាំងនោះ មិនប្រាកដជាមានភាពទាក់ទងជាមួយនឹងការអនុវត្តច្បាប់ ដែលអាចត្រូវបកស្រាយបានច្រើនជាងមួយ ឬមានភាពទាក់ទងជាមួយនឹងការវាយតម្លៃទៅលើអង្គហេតុដែលពាក់ព័ន្ធនោះឡើយ[៦៥]។

៤៦. នៅក្នុងសាលដីការបស់ខ្លួន ("សាលដីកា SMD") អង្គបុរេជំនុំជម្រះបានរកឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ ដោយធ្វើការបកស្រាយមិនត្រឹមត្រូវទៅ

[៦៥] សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ស្នើសុំឱ្យចាត់វិធានការសមរម្យពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួនរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន តតាំងពីឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រម Katinka Lahuis និងចៅក្រម Rowan Downing ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ០០២/២០-១០-២០០៩-អវតក(អបជ០៣) ឯកសារលេខ ០៥ កថាខណ្ឌ ៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

លើកាតព្វកិច្ចរបស់ខ្លួន ទាក់ទងទៅនឹងការស្វែងរកភស្តុតាងដោះបន្ទុក[៦៦]។ អ្នកដាក់ពាក្យបណ្តឹង នៅពេលនេះ កំពុងតែផ្អែកលើការរកឃើញនេះ ដើម្បីចោទប្រកាន់ថាមានភាពលម្អៀងកើតចេញពីចៅក្រម Lemonde ដោយហេតុថា ការបកស្រាយមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេត អំពីកាតព្វកិច្ចរបស់ខ្លួន "បង្ហាញថា ក.ស.ច.ស មិនបានស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដោយអនាគតិនោះទេ ហើយចំណុចនេះគាំទ្រដល់ការពោលថ្លែងរបស់ចៅក្រម Lemonde នៅក្នុងកិច្ចប្រជុំមួយ កាលពីដើមខែសីហា ឆ្នាំ២០០៩"[៦៧]។

៤៧. អង្គបុរេជំនុំជម្រះរកឃើញថា កំហុសអង្គច្បាប់ដែលបង្កើតឡើងដោយសហចៅក្រមស៊ើបអង្កេតមិននាំឱ្យមានការចោទប្រកាន់ថា មានភាពលម្អៀង ឬការលេចចេញឱ្យឃើញនូវភាពលម្អៀងកើតចេញពីចៅក្រម Lemonde នោះទេ ដោយសារចៅក្រម Lemonde គឺជាចៅក្រមមួយរូបក្នុងចំណោមចៅក្រមដែលមានកំហុស។

៤៨. អង្គបុរេជំនុំជម្រះរកឃើញបន្ថែមទៀតថា សហមេធាវីការពារក្តីខកខានមិនបានបង្ហាញថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់នោះ ជាពិសេសតួនាទីរបស់ចៅក្រម Lemonde ក្នុងការសម្រេចនេះ ថាជា ឬអាចឱ្យគេយល់ឃើញយ៉ាងសមហេតុផលថាជា បុរេវិនិច្ឆ័យប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹង ហើយសេចក្តីសម្រេចនោះ មិនប្រាកដជាមានភាពទាក់ទងជាមួយនឹងការអនុវត្តច្បាប់ ដែលអាចត្រូវបកស្រាយបានច្រើនជាងមួយ ឬមានភាពទាក់ទងជាមួយនឹងការវាយតម្លៃទៅលើអង្គហេតុដែលពាក់ព័ន្ធនោះឡើយ[៦៨]។

---

៦៦ សា ៣លដីកាលើបណ្តឹងឧទ្ធរណ៍ពីដីកាសម្រេចលើសំណើស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD) ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៤) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៣៨។

៦៧ ពាក្យបណ្តឹង អៀង ធីរិទ្ធ កថាខណ្ឌ ៣១។

៦៨ សេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ នួន ជា ប្តឹងជំទាស់ចិត្តចំពោះចៅក្រម Marcel Lemonde ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ០០២-២៩-១០-២០០៩-អវតក/អបជ(០៤) ឯកសារលេខ ០៤ កថាខណ្ឌ ២៣។

## ៤. *ភាពស្អាក់ស្ទើរក្នុងការកំណត់សម្ភារៈឯកសារដោះបន្ទុក នៅក្នុងដីកាសម្រេចពន្យារចិរៈវេលាឃុំខ្លួន*

៤៩. សហមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ បានធ្វើសេចក្ដីសន្និដ្ឋានទៅលើការចោទប្រកាន់នេះ នៅក្នុងផ្នែកមួយនៃពាក្យបណ្ដឹងរបស់ខ្លួន ទាក់ទងទៅនឹងដីកាសម្រេច SMD ដូចបានរៀបរាប់ខាងលើ ហើយគ្រាន់តែយោងទៅលើកថាខណ្ឌមួយនៅក្នុងដីកាសម្រេចលើការឃុំខ្លួនតែប៉ុណ្ណោះ។ តាមការលើកឡើងរបស់សហមេធាវីការពារក្ដី "ភាពស្អាក់ស្ទើររបស់ចៅក្រម Lemonde ក្នុងការកំណត់សម្ភារៈឯកសារថាជាភស្តុតាងដោះបន្ទុក នៅក្នុងដីកាសម្រេចឃុំខ្លួន ដែលបន្តការឃុំខ្លួនជនត្រូវចោទបន្ថែមមួយឆ្នាំទៀតនោះ គឺជាភស្តុតាងបន្ថែមទៀត ដើម្បីបញ្ជាក់ពីភាពលម្អៀងរបស់ចៅក្រម Lemonde ដែលមានរួចជាស្រេចក្នុងការសម្រេចថាជនត្រូវចោទមានទោស"[៦៩]។

៥០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាសម្រេចលើការឃុំខ្លួនកំពុងត្រូវបានប្ដឹងឧទ្ធរណ៍ នៅពេលមានការដាក់ពាក្យបណ្ដឹងរបស់ អៀង ធីរិទ្ធ។ នៅក្នុងបណ្ដឹងឧទ្ធរណ៍នោះ សហមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ ក៏បានលើកឡើងនូវការចោទប្រកាន់ស្រដៀងគ្នានេះដែរ។ អង្គបុរេជំនុំជម្រះធ្វើសេចក្ដីយោងទៅលើការរកឃើញរបស់ខ្លួន នៅក្នុងសាលដីកាស្ដីពីការឃុំខ្លួនបណ្ដោះអាសន្នទាក់ទងនឹងចំណុចនេះ ហើយច្រានចោលការចោទប្រកាន់នេះ[៧០]។ ដោយសារអង្គហេតុត្រូវបានរកឃើញថា មិនមានភាពត្រឹមត្រូវ អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់នោះមិននាំឱ្យឈានទៅដល់ការចោទប្រកាន់ពីភាពលម្អៀង ឬការលេចចេញឱ្យឃើញនូវភាពលម្អៀងនោះទេ។

## ៥. *មតិយោបល់ដែលបានផ្ដល់ឱ្យទៅបណ្ដាញសារព័ត៌មាន*

ត្រា៖ អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

---

[៦៩] ពាក្យបណ្ដឹង អៀង ធីរិទ្ធ កថាខណ្ឌ ៣២។

[៧០] សាលដីកាសាធារណៈដែលត្រូវបានកោសលុប លើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលាក្នុងឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៣) ឯកសារលេខ C20/9/15 កថាខណ្ឌ ២៣។

00533255



៥១. អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសាលដីកាលើបណ្តឹងមិនទុកចិត្តពីពេលមុនថា សេចក្តីថ្លែងអះអាងរបស់បុគ្គលម្នាក់ ដែលត្រូវបានដកស្រង់នៅក្នុងសារព័ត៌មាន មិនអាចយកមកធ្វើជាភស្តុតាងដែលគួរឱ្យទុកចិត្តបានទេ[៧១]។ ដោយគ្មានភស្តុតាងផ្សេងពីនេះទាក់ទងនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ មិនបានបង្ហាញពីភាពលម្អៀង ឬការលេចចេញឱ្យឃើញនូវភាពលម្អៀង ដែលត្រូវបានចោទប្រកាន់នោះទេ។

*៦. ការកែប្រែរបាយការណ៍វាយតម្លៃរបស់បុគ្គលិកម្នាក់*

៥២. អង្គបុរេជំនុំជម្រះរកឃើញថា ការបញ្ចេញមតិយោបល់របស់ចៅក្រមទាក់ទងនឹងការវាយតម្លៃលើបុគ្គលិក មិនអាចឱ្យបុគ្គលចេះដឹងម្នាក់ ដែលដឹងឮនូវស្ថានភាពពាក់ព័ន្ធទាំងអស់ យល់ថាមានអត្ថិភាពនៃភាពលម្អៀង ដែលនឹងនាំឱ្យមានបណ្តឹងមិនទុកចិត្តចំពោះចៅក្រមនោះ លុះត្រាណាមានភស្តុតាងមកបង្ហាញថា អង្គហេតុនេះមានភាពពាក់ព័ន្ធជាមួយនឹងរឿងក្តី ហើយប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ។

៥៣. សេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin លើកឡើងថា ចៅក្រម Lemonde បានបញ្ចេញមតិយោបល់ខុសគ្នាពីមតិយោបល់របស់លោក Bastin ចំពោះការវាយតម្លៃទៅលើបុគ្គលិកម្នាក់។ ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសាលដីកាមុនៗ និងថ្មីៗនេះ បទដ្ឋានសម្រាប់ច្រានចោលនូវសច្ចធារណ៍នៃអនាគតិ មានកម្រិតខ្ពស់ ហើយនៅក្នុងករណីនេះ ការច្រានចោលនេះមិនអាចធ្វើទៅបាន ដោយគ្រាន់តែផ្អែកទៅលើភាពខុសគ្នានៃមតិយោបល់ណាមួយ ដែលយកមកធ្វើជាមូលដ្ឋានសម្រាប់ប្តឹងមិនទុកចិត្តចំពោះចៅក្រមឡើយ។ អង្គបុរេជំនុំជម្រះរកឃើញថា សហមេធាវីការពារក្តីរបស់ជនត្រូវចោទមិនបានបង្ហាញថា មានភាពលម្អៀងសត្យានុម័ត ឬអត្តនោម័តណាមួយរបស់ចៅក្រម Lemonde ប្រឆាំងទៅនឹងជនត្រូវចោទនោះទេ។

---

[៧១] សេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ ខៀវ សំផន ប្តឹងមិនទុកចិត្តចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde សំណុំរឿងលេខ ០០២/១៣-១០-២០០៩-អវតក/អបជ(០២) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ៧ កថាខណ្ឌ ៣០។

## ៧. *បញ្ហាក្នុងការប្រើប្រាស់យុទ្ធសាស្ត្រ ទាក់ទងទៅនឹងចម្លើយសាក្សីនិងការសង្ខេបចម្លើយសាក្សី*

៥៤. ទាក់ទងទៅនឹងការចោទប្រកាន់នេះ ដែលលើកឡើងនៅក្នុងពាក្យបណ្តឹងរបស់ អៀង សារី អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីបានលើកឡើងពីបញ្ហា "ភាពមិនប្រក្រតីនៃការស៊ើបសួរ" របស់ចៅក្រម Lemonde ដែលបណ្តាលមកពីការប្រើយុទ្ធសាស្ត្រការងារ ដែលសហមេធាវីការពារក្តីយល់ឃើញថា អាចនាំឱ្យមានភាពមិនពិតប្រាកដនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី។ កំណត់ហេតុទាំងនេះត្រូវបានវិភាគដោយសមាជិកក្រុមការងាររបស់ ក.ស.ច.ស ដែលបុគ្គលទាំងនេះក៏ត្រូវរងការចោទប្រកាន់ថាខ្វះជំនាញវិជ្ជាជីវៈក្នុងការងារនេះផងដែរ។

៥៥. អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមទៀតថា នៅក្នុងពាក្យបណ្តឹងរបស់ខ្លួន សហមេធាវីការពារក្តីមិនបានផ្តល់ឱ្យនូវទស្សីករណ៍ទាំងឡាយណា ដើម្បីគាំទ្រការចោទប្រកាន់នេះឡើយ។ សហមេធាវីការពារក្តី គ្រាន់តែផ្អែកទៅលើអង្គហេតុទាក់ទងនឹងសេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin តែប៉ុណ្ណោះ[៧២] ដោយអះអាងយ៉ាងសាមញ្ញថា សេចក្តីថ្លែងការណ៍នោះ "លាតត្រដាងពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់តុលាការ និងភាពមិនប្រក្រតីនៃការស៊ើបសួរមួយចំនួន"[៧៣]។

៥៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់នេះខ្វះមូលដ្ឋានអង្គហេតុ។ សហមេធាវីការពារក្តីមិនបានបង្ហាញអត្ថិភាពនៃភាពលម្អៀងសត្យានុម័ត ឬអត្តនោម័តណាមួយ ដែលតម្រូវឱ្យច្រានចោលសច្ចធារណ៍នៃអនាគតិរបស់ចៅក្រមបាននោះទេ។

## ៨. *លទ្ធភាពនៃការប្រើប្រាស់ "ប្រព័ន្ធទិន្នន័យសាក្សីផ្ទៃក្នុង"*

---

[៧២] សេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin ទំព័រ ២-៣។

[៧៣] ពាក្យបណ្តឹង អៀង សារី កថាខណ្ឌ ១។

00533257



៥៧. នៅក្នុងពាក្យបណ្តឹងរបស់ អៀង សារី សហមេធាវីការពារក្តីផ្អែកទៅលើសេចក្តីថ្លែង-ការណ៍ទីពីររបស់លោក Bastin ដើម្បីគាំទ្រការចោទប្រកាន់របស់ខ្លួន ទៅលើការប្រព្រឹត្តមិនត្រឹមត្រូវរបស់ចៅក្រម Lemonde នៅពេលដែលចៅក្រម "បានបញ្ជាថា គ្រប់បុគ្គលិកទាំងអស់មានសិទ្ធិចូលមើលប្រព័ន្ធទិន្នន័យសាក្សីផ្ទៃក្នុង ដែលគួរតែត្រូវបានប្រគល់ឱ្យបុគ្គលិកទាំងឡាយណាដែលបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍សមរម្យតែប៉ុណ្ណោះ"[៧៤]។ ពាក្យបណ្តឹងរបស់ អៀង សារី មិនបានផ្តល់ឱ្យនូវទឡ្ហីករណ៍បន្ថែមណាមួយ ដើម្បីគាំទ្រការចោទប្រកាន់នេះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងពាក្យបណ្តឹងរបស់ អៀង ធីរិទ្ធ មានការចោទប្រកាន់ថា "ចៅក្រម Lemonde បានប៉ុនប៉ងកំហិតការប្រើប្រាស់ 'ប្រព័ន្ធទិន្នន័យសាក្សីផ្ទៃក្នុង' ឱ្យមកត្រឹមតែបុគ្គលិកអន្តរជាតិនៃ ក.ស.ច.ស តែប៉ុណ្ណោះដែលអាចប្រើប្រាស់បាន"[៧៥]។ ពាក្យបណ្តឹងរបស់ អៀង ធីរិទ្ធ និងពាក្យបណ្តឹងរបស់ អៀង សារី ផ្អែកទៅលើអង្គហេតុដូចគ្នា ដែលពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍ទីពីរ របស់លោក Bastin[៧៦]។

៥៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហមេធាវីការពារក្តីរបស់ អៀង សារី ទំនងជារិះគន់ដល់ចៅក្រម Lemonde ចំពោះការសម្រេចថា បុគ្គលជាច្រើនត្រូវបានអនុញ្ញាតឱ្យប្រើ-ប្រាស់ប្រព័ន្ធទិន្នន័យនេះ ជៀសជាង "ក្រុមអ្នកស៊ើបអង្កេតដែលបានទទួលការបណ្តុះបណ្តាលយ៉ាងជំនាញ" ដែលប្រព័ន្ធទិន្នន័យនេះត្រូវបានបង្កើតឡើងសម្រាប់អ្នកស៊ើបអង្កេតបែបនេះ។ ចំណែកឯសហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ វិញ ហាក់ដូចជារិះគន់ចៅក្រម Lemonde ចំពោះការកំហិតការប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះ ឱ្យតែ 'ខាងអន្តរជាតិ' នៃ ក.ស.ច.ស សម្រាប់ប្រើប្រាស់តែប៉ុណ្ណោះ។ អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមថា នៅក្នុងសេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin មានការលើកឡើងថា ទាំងសហចៅក្រមស៊ើបអង្កេតជាតិ និងអ្នកប្រឹក្សាច្បាប់របស់គាត់ អាចប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះបាន តាំងពីឆ្នាំ២០០៧ មកម្ល៉េះ[៧៧]។

---

[៧៤] ពាក្យបណ្តឹង អៀង សារី កថាខណ្ឌ ១(ឃ)។

[៧៥] ពាក្យបណ្តឹង អៀង ធីរិទ្ធ កថាខណ្ឌ ១១(ច)។

[៧៦] សេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin ទំព័រ ៨-១០។

[៧៧] សេចក្តីថ្លែងការណ៍ទីពីររបស់ Bastin ទំព័រ ១០។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៥៩. ក្រៅពីការសង្កេតឃើញថា ពាក្យបណ្តឹងរបស់ អៀង សារី រួមគ្នាជាមួយពាក្យបណ្តឹងរបស់ អៀង ធីរិទ្ធ ដែលពាក្យបណ្តឹងទាំងពីរនេះ លើកទឡ្ហីករណ៍ផ្ទុយគ្នាលើបញ្ហាតែមួយ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា តើគោលការណ៍នៃការប្រើប្រាស់ប្រព័ន្ធទិន្នន័យផ្ទៃក្នុងណាមួយរបស់ ក.ស.ច.ស អាចជាឧទាហរណ៍បញ្ជាក់ពីអត្ថិភាពនៃភាពលម្អៀងសត្យានុម័ត ឬអត្តនោម័តដែលប្រឆាំងនឹងជនត្រូវចោទនោះទេ។ ជាថ្មីម្តងទៀត សហមេធាវីការពារក្តីបានរិះគន់ទៅលើគោលការណ៍ដែលអនុវត្តដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសេចក្តីសម្រេចរបស់គាត់ដែលពាក់ព័ន្ធជាមួយ ក.ស.ច.ស ដោយសហមេធាវីការពារក្តីមិនបានផ្តល់ឱ្យនូវមូលដ្ឋានអង្គហេតុណាមួយ ដើម្បីគាំទ្រការអះអាងថា សច្ចធារណ៍នៃអនាគតិរបស់ចៅក្រមត្រូវច្រានចោល នៅពេលមានភាពលម្អៀងសត្យានុម័ត ឬអត្តនោម័តណាមួយប្រឆាំងនឹងជនត្រូវចោទ។

*៩. ការស្តាប់ចម្លើយ និងការថតរូបភាពវីដេអូ សាក្សីសំខាន់ៗ និងការចោទប្រកាន់ពីភាពលម្អៀងសម្រាប់ 'ខាងអន្តរជាតិ' នៃ ក.ស.ច.ស (ព័ត៌មានត្រូវបានលាក់ពីខាងជាតិ)*

៦០. ផ្អែកលើសេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ អះអាងថា (១) ចៅក្រម Lemonde "ព្យាយាមយ៉ាងសកម្មក្នុងការផ្ទុកទុកព័ត៌មានពីខាងជាតិនៃ ក.ស.ច.ស ហើយមានតែ 'ខាងអន្តរជាតិ' តែមួយគត់អាចទទួលព័ត៌មាននោះ"[៧៨] និង (២) ចៅក្រម Lemonde ខ្វះសុច្ចរិតភាព ដោយបានអនុញ្ញាតឱ្យក្រុមថតភាពយន្ត "ថតយកការស្តាប់ចម្លើយសាក្សីផ្ទៃក្នុងសំខាន់ៗជាសម្ងាត់"[៧៩]។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

---

[៧៨] ពាក្យបណ្តឹង អៀង ធីរិទ្ធ កថាខណ្ឌ ៣៨-៤៥។

[៧៩] ពាក្យបណ្តឹង អៀង ធីរិទ្ធ កថាខណ្ឌ ៤៦-៥០។ យោងតាមសហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ លោកចៅក្រម Lemonde បានអនុញ្ញាតឱ្យក្រុមអ្នកថតរូបភាពវីដេអូ រួមដំណើរជាមួយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នៅពេលធ្វើបេសកកម្មស្តាប់ចម្លើយសាក្សីផ្ទៃក្នុងសំខាន់ម្នាក់ ដោយគ្មានការយល់ព្រមពីលោកចៅក្រម យូ ប៊ុនឡេង ឬគ្មានការជូនដំណឹងឱ្យគាត់បានដឹង។

៦១. សហមេធាវីការពារក្តីរបស់ អៀង សារី ក៏ផ្អែកទៅលើចំណុចនេះដែរ នៅក្នុងសេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin ក្នុងការបង្ហាញពីកង្វះសុច្ចរិតភាពរបស់ចៅក្រម Lemonde ដែលបានអនុញ្ញាតឱ្យក្រុមថតភាពយន្តទទួលបាននូវព័ត៌មានពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ដែលជាឋានានុក្រមមន្ទីរ ស-២១[៨០]។

៦២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin រៀបរាប់អំពីព័ត៌មានដែលលោក Bastin បានទទួលតាមការឮគេនិយាយពីមាត់មួយទៅមាត់មួយ។ សេចក្តីថ្លែងការណ៍ត្រូវបានយកមកគាំទ្រពាក្យបណ្តឹងរបស់ អៀង សារី និងពាក្យបណ្តឹងរបស់ អៀង ធីរិទ្ធ ដើម្បីប្តឹងជំទាស់ចំពោះចៅក្រម Lemonde។

៦៣. អង្គបុរេជំនុំជម្រះរំលឹកផងដែរថា "បញ្ហាដែលជាធម្មតាមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់លក្ខខណ្ឌដកហូតសិទ្ធិចៅក្រមនោះ គឺ 'ការប៉ាន់ប្រមាណ ជំនឿ ការសន្និដ្ឋាន ការសង្ស័យ ការផ្តល់មតិយោបល់ ព្រមទាំងបញ្ហាមិនមានភាពជាក់ស្តែងស្រដៀងគ្នានានា"[៨១]។ បណ្តឹងជំទាស់ចំពោះចៅក្រមតម្រូវឱ្យភាគីដាក់ពាក្យបណ្តឹងនោះ បង្ហាញឱ្យឃើញថា ចៅក្រមដែលរងការប្តឹងមានភាពលម្អៀងសត្យានុម័ត ឬបង្ហាញថាមានការលេចចេញឱ្យឃើញនូវភាពលម្អៀងនោះ។ ដូចដែលបានអះអាងពីខាងលើរួចហើយ លក្ខខណ្ឌតម្រូវ ដើម្បីធ្វើការច្រានចោលសច្ចធារណ៍នៃអនាគតិរបស់ចៅក្រមណាមួយ មានកម្រិតខ្ពស់។ ហេតុដូច្នេះ នៅពេលដែលបន្ទុកក្នុងការបង្ហាញភស្តុតាងនេះមិនត្រូវបានបំពេញ អង្គបុរេជំនុំជម្រះមិនត្រូវបានតម្រូវឱ្យធ្វើការដោះស្រាយទៅលើពាក្យបណ្តឹងនេះឡើយ[៨២]។ អង្គបុរេជំនុំជម្រះរកឃើញថា សេចក្តីថ្លែងការណ៍ទីពីររបស់លោក Bastin មិនបានផ្តល់ឱ្យនូវមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ ដើម្បីច្រានចោលសច្ចធារណ៍នៃអនាគតិរបស់ចៅក្រម Lemonde ទេ។ លើសពីនេះ សេចក្តីថ្លែងការណ៍រួមជាសាធារណៈរបស់សហចៅក្រមស៊ើបអង្កេតទាំងពីររូបបង្ហាញថា មិនទំនងជាមានការខ្វែងយោបល់គ្នារវាង

---

[៨០] ពាក្យបណ្តឹង អៀង សារី កថាខណ្ឌ ១(គ)។

[៨១] សេចក្តីសម្រេចលើបណ្តឹងជំទាស់ អបជ០៣ កថាខណ្ឌ ៨។

[៨២] សេចក្តីសម្រេចលើបណ្តឹងជំទាស់ អបជ០៣ កថាខណ្ឌ ១០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ចៅក្រមទាំងពីររូបនេះ ដូចបានចោទប្រកាន់ឡើងដោយសហមេធាវីការពារក្តីរបស់ជនត្រូវចោទទេ[៨៣]។ អង្គបុរេជំនុំជម្រះរកឃើញបន្ថែមថា បើទោះជាមានភស្តុតាងគ្រប់គ្រាន់ក៏ដោយ ក៏ការចោទប្រកាន់នោះ មិនទាំឱ្យឈានទៅដល់ការចោទប្រកាន់ពីភាពលម្អៀង ឬការលេចចេញឱ្យឃើញនូវភាពលម្អៀងដែរ។

៦៤. ទាក់ទងទៅនឹងទឡ្ហីករណ៍ដែលលើកឡើងដោយសហមេធាវីការពារក្តីរបស់ នួន ជា នៅក្នុងការគាំទ្រការចោទប្រកាន់ពីភាពលម្អៀងរបស់ចៅក្រម Lemonde នៅពេលលោកចៅក្រម "ហាក់ដូចជាបំពេញកិច្ចតែម្ខាង ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ ក.ស.ច.ស ដើម្បីទទួលបាននូវសក្ខីកម្មរបស់ [redacted] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទឡ្ហីករណ៍នេះត្រូវបានច្រានចោលម្តងរួចមកហើយនៅក្នុងសាលដីកាពីលើកមុន[៨៤]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានទឡ្ហីករណ៍ថ្មីណាមួយ ទាក់ទងទៅនឹងបញ្ហានេះត្រូវបានលើកឡើងនោះទេ។

៦៥. ទាក់ទងទៅនឹងសំណើសុំច្បាប់ចម្លងនៃកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ រវាងក្រុមអ្នកថតភាពយន្តបារាំង និង ក.ស.ច.ស ក៏ដូចជាការរឹបអូសយកខ្សែអាត់រូបភាពវីដេអូ និង/ឬសម្លេងទាំងអស់ដែលក្រុមអ្នកថតខ្សែភាពយន្តបានថតរួច ស្របតាមកិច្ចព្រមព្រៀងនេះដើម្បី "ជួយដល់ អ.ប.ជ ក្នុងការសម្រេចរបស់ខ្លួនលើបណ្តឹងជំទាស់" អង្គបុរេជំនុំជម្រះសូមយោងទៅលើសេចក្តីសម្រេចរបស់ខ្លួនពីលើកមុនចំពោះបញ្ហានេះ[៨៥]។

៦៦. ដូចដែលអង្គបុរេជំនុំជម្រះបានរកឃើញហើយថា រាល់ការលើកឡើងនីមួយៗជាមូលដ្ឋាននៃការចោទប្រកាន់ពីភាពលម្អៀង ឬការលេចចេញឱ្យឃើញនៃភាពលម្អៀងដែលត្រូវបាន

---

[៨៣] សេចក្តីថ្លែងការណ៍របស់ ក.ស.ច.ស ស្តីពីការចុះស៊ើបអង្កេតដល់កន្លែង http://www.eccc.gov.kh/english/cabinet/press/60/Press_release_OCIJ_reconstruction_recording.pdf ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៨។

[៨៤] សាលដីកាលើពាក្យបណ្តឹង ជំទាស់របស់ នួន ជា កថាខណ្ឌ ២២។

[៨៥] សូមប្រៀបធៀបឯកសារខាងលើ កថាខណ្ឌ ២៩ ដល់ កថាខណ្ឌ ៣៥។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00533261



ចោទប្រកាន់ មិនបានគាំទ្រការចោទប្រកាន់នោះឡើយ។ ហេតុដូច្នេះ ការលើកឡើងទាំងនោះ មិនបានបង្ហាញជារួមនូវភាពលម្អៀង ឬការយល់ឃើញថាមានភាពលម្អៀងទេ។

*បញ្ហាផ្សេងៗទៀត*

៦៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនបានដោះស្រាយតែទៅលើបញ្ហាដែលលើកឡើងនៅក្នុងពាក្យបណ្ដឹងតែប៉ុណ្ណោះ ដែលអាចត្រូវបានចាត់ទុកថាជាមូលដ្ឋាននៃការចោទប្រកាន់ពីភាពលម្អៀង ឬការលេចចេញឲ្យឃើញនូវភាពលម្អៀង។ អង្គបុរេជំនុំជម្រះមិនបានពិចារណាទៅលើសារណា ដែលមិនពាក់ព័ន្ធទៅនឹងការសម្រេចទាំងនេះទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ÷**

១. ទទួលយកពាក្យបណ្ដឹងទាំងនេះ។

២. ច្រានចោលពាក្យបណ្ដឹងទាំងនេះ ចាត់ទុកថាឥតបានការ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **នេយ ថុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**